ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៩៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋានជាតិកម្ពុជា នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ជាអក្សរឡាតាំង National Secretariat of Cambodia for Mekong-Lancang Cooperation (NSC-MLC)

ដើម្បីសម្របសម្រួលការងារសហប្រតិបត្តិការ នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ជាមួយប្រទេសសមាជិកដទៃទៀត និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ២.-**

លេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង មានតួនាទីដូចខាងក្រោម៖

- សម្របសម្រួលការងាររវាងក្រសួង-ស្ថាប័នពាក់ព័ន្ធកម្ពុជាទាំងអស់ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង
- តម្កល់ព័ត៌មាន របាយការណ៍ និងឯកសារនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង
- សម្របសម្រួលថ្នាក់ជាតិនូវការអនុវត្តសេចក្តីសម្រេចនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង
- សម្របសម្រួល និងរៀបចំកិច្ចប្រជុំ និងឯកសារនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង
- ផ្សព្វផ្សាយការយល់ដឹងពីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង

**មាត្រា ៣.-**

សមាសភាពនៃលេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ឥស្សរជនជាន់ខ្ពស់ទទួលបន្ទុកការងារជាឧត្តមមន្ត្រីនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងកម្ពុជានៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២. | អនុរដ្ឋលេខាធិការទទួលបន្ទុកកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣. | ឧត្តមមន្ត្រីនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤. | ឧត្តមមន្ត្រីនៃក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៥. | ឧត្តមមន្ត្រីនៃក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៦. | ឧត្តមមន្ត្រីនៃក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៧. | ឧត្តមមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៨. | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៩. | តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១០. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១. | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. | តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣. | តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ១៤. | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

១៥.តំណាងក្រសួងទេសចរណ៍ សមាជិក
១៦.តំណាងក្រសួងសុខាភិបាល សមាជិក
១៧.តំណាងក្រសួងបរិស្ថាន សមាជិក
១៨.តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
១៩.តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
២០.តំណាងក្រសួងកិច្ចការនារី សមាជិក
២១.តំណាងក្រសួងធម្មការ និងសាសនា សមាជិក
២២.តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
២៣.តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
២៤.ប្រធាននាយកដ្ឋានសហប្រតិបត្តិការមេគង្គ នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លេខាធិការ

**មាត្រា ៤.-**

សមាសភាពប្រធាន អនុប្រធាន សមាជិក និងលេខាធិការ នៃលេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ៥.-**

លេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង មានទីតាំងនៅទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ៦.-**

ប្រធានលេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង អាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំ និងធ្វើរបាយការណ៍ក្នុងករណីចាំបាច់ ដើម្បីពិភាក្សា និងដោះស្រាយរាល់បញ្ហានានានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

**មាត្រា ៧.-**

ក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ចដឹកនាំក្រុមការងាររួមតាមវិស័យអាទិភាពគន្លឹះនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ត្រូវធ្វើរបាយការណ៍កិច្ចប្រជុំ និងលទ្ធផលការងារជូនរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងចម្លងជូនលេខាធិការដ្ឋានជាតិកម្ពុជានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

**មាត្រា ៨.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ខែមិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ